# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៩០ សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមលើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៣

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែមិនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ០០៤ ប្រក/សហវ/ពជ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការផ្តល់រង្វាន់ជូនអង្គភាពពន្ធដារ

- បានឃើញប្រកាសលេខ ២៨៧ សហវ/ពដ ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបែងចែកប្រាក់រង្វាន់របស អង្គភាពពន្ធដារ
- បានឃើញប្រកាសលេខ ៨៨៦ សហវ/ពដ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០០៣ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៣
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ ឆ្នាំ២០០៣

## សំរេច

**ប្រការ ១ :** ចាប់ពីថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០០៤តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលមិនបានមកបង់ពន្ធសំរាប់ឆ្នាំ២០០៣ ដូចបានកំណត់ក្នុងប្រការ ១ នៃប្រកាសលេខ ៨៨៦ សហវ.ពដ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០០៣ ។

ប្រាក់ពិន័យដែលទទួលបានមកអំពីការពិន័យលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ (នៅទីចំណតនានា) ដែលមានសហការរវាងមន្ត្រីពន្ធដារ និងមន្ត្រីមានសមត្ថកិច្ចដែលបានចូលរួម ត្រូវបានអនុញ្ញាតឱ្យដកចំនួន ៣៥% (សាមសិបប្រាំភាគរយ) លើប្រាក់ដែលពិន័យបាន សំរាប់ប្រើប្រាស់ជាប្រាក់រង្វាន់ ដោយត្រូវបែងចែកដូចតទៅ :

- ៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ក្នុងនោះមានមន្ត្រីពន្ធដារ និង មន្ត្រីមានសមត្ថកិច្ចដែលបានចូលរួម ។
- ២០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាខាពន្ធដារខេត្ត-ក្រុង
- ១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខេត្ត-ក្រុង ។
- ១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខ័ណ្ឌ-ស្រុក ។

២-ប្រាក់ពិន័យដែលទទួលបានលើការត្រួតពិនិត្យក្នុងភូមិ ឃុំ-សង្កាត់ ដែលមានសហការរវាងមន្ត្រីពន្ធដារ នគរបាលឃុំ-សង្កាត់ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបានអនុញ្ញាតឱ្យដកចំនួន ៣៥% (សាមសិបប្រាំភាគរយ) លើប្រាក់ដែលពិន័យបាន សំរាប់ប្រើប្រាស់ជាប្រាក់រង្វាន់ ដោយត្រូវបែងចែកដូចតទៅ :

-៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ក្នុងនោះមាន មន្ត្រីពន្ធដារ នគរបាលឃុំ-សង្កាត់ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-២០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយ សំរាប់សាខាពន្ធដារខេត្ត-ក្រុង(១០%) សំរាប់នគរបាលឃុំ-សង្កាត់ (៥%) និងសំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ (៥%)

-១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខេត្ត-ក្រុង ។

-១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខ័ណ្ឌ-ស្រុក ។

**ប្រការ ២ :** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិនា ឆ្នាំ២០០៤

គាត ឈន់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជារបាយការណ៍"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង

  "ដើម្បីជូនជ្រាបជាពតិមាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

  "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ